# ចម្លាក់ព្រះឥសូរក្នុងទម្រង់ភិក្សាដនមូត្តិ

ព្រះឥសូរ គឺជាទេពធំជាងគេនៅក្នុងព្រហ្មញ្ញសាសនា ដែលមានតួនាទីបង្កើតលោក និង បំផ្លាញលោកចាស់ដើម្បីបង្កើតលោកថ្មី។[១] ព្រះឥសូរមានព្រះនេត្របី មានចំណិតព្រះចន្ទ្រលើផ្នួង សក់ ព្រះហស្តពីរ បួន ប្រាំបី និងដប់ ហើយភាគច្រើនតែងមានយានជំនិះជាសត្វគោនន្ទិ និងពេល ខ្លះជិះសត្វតោក៏មាន។ នៅក្នុងសិល្បៈខ្មែរ សិល្បករបុរាណបានបង្ហាញព្រះឥសូរច្រើនទម្រង់ មាន ដូចជា សិវនាដរាជមូត្តិ សិវវ្រិសវាហនមូត្តិ សិវត្រិមូត្តិ សិវទក្សិនមូត្តិ សិវឧមាមហេស្វរមូត្តិ សទាសិវ សិវភិក្សាដនមូត្តិ ។ល។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញទម្រង់មួយរបស់ព្រះឥសូរ គឺទម្រង់ សិវភិក្សាដនមូត្តិ ដែលជាការបង្ហាញព្រះឥសូរក្នុងទម្រង់ជាមនុស្សជំទង់ដើរសុំទាន មានរូបរាង សង្ហា និងអាក្រាតកាយ។ តើចម្លាក់សិវភិក្សាដនមូត្តិក្នុងសិល្បៈខ្មែរមានលក្ខណៈបែបណាខ្លះ?

ទេវកថារឿងសិវភិក្សាដនមូត្តិ មាននិទាននៅក្នុងគម្ពីរជាច្រើននៃព្រហ្មញ្ញសាសនា។ ក្នុង នោះគម្ពីរកុម៌បុរាណរៀបរាប់ថា៖ "ព្រះព្រហ្មបានប្រកាសប្រាប់ពួកព្រាហ្មណ៍ដោយក្រអឺតក្រទម ថា ទ្រង់គឺជាអាទិទេពកំពូលនិងជាអ្នកបង្កើតលោក។ រំពេចនោះ ព្រះសិវចេញមកជាសសរភ្លើង មួយជំទាស់ជាមួយព្រះព្រហ្ម ព្រោះទ្រង់យល់ថាព្រះអង្គគឺជាអ្នកបង្កើតលោកពិតប្រាកដ។ ពួក ព្រាហ្មណ៍ទទួលស្គាល់ព្រះសិវ តែព្រះព្រហ្មនៅតែចចេសរឹងរូសមិនយល់ស្រប ដែលធ្វើឱ្យព្រះសិវ ក្រោធខឹងនិងប្រែក្រឡាទៅជាតួអង្គកាចសាហាវមួយរំពេចដែលមានឈ្មោះថា ភៃរវ ហើយបាន យកក្រចកដៃកាត់ព្រះសិរទីប្រាំរបស់ព្រះព្រហ្ម។ ដើម្បីលុបលាងនូវបាបកម្មដែលបានកាត់ព្រះ សិរព្រះព្រហ្ម ព្រះសិវត្រូវកាន់លលាដ៍ព្រះសិររបស់ព្រះព្រហ្មធ្វើជាចានដើរសុំទានទាំងអាក្រាត កាយក្នុងរូបរាងជាឥសីក្មេងមានរូបរាងសង្ហា។ ទ្រង់បានធ្វើដំណើរវង្វេងមកដល់ព្រៃទារុកវន ក៏ បានជួបស្ត្រីជាច្រើនជាប្រពន្ធពួកឥសី។ ដោយទ្រង់មានរូបរាងកាយសង្ហា ស្ត្រីទាំងនោះបានលង់ ស្នេហ៍ព្រះសិវ ហើយបានដើររាំ និងស្រែកច្រៀងតាមផ្លូវដោយមិនខ្វល់ពីការរបូតអាវរបស់ពួក នាងឡើយ។ ក្រោយមក អ្នកសុំទានរូបរាងសង្ហាក៏បានធ្វើដំណើរទៅដល់ទេវស្ថានព្រះវិស្ណុ។ អ្នក យាមទ្វារទេវស្ថានព្រះវិស្ណុម្នាក់ឈ្មោះ វិស្វក្សេន បានហាមឃាត់មិនអនុញ្ញាតឱ្យចូល ធ្វើឱ្យព្រះសិវ ខឹងក៏សម្លាប់អ្នកយាមនោះដោយលើកសពយកដាក់នៅលើត្រីសូល៍ ដែលកាន់តែធ្វើឱ្យបន្ថែម បាបដល់ទ្រង់។ ទម្រង់ដែលព្រះសិវលើកសពអ្នកយាមទ្វារដាក់លើត្រីសូល៍នេះគេឱ្យឈ្មោះថា កង្កាលមូត្តិ។ កង្កាល បានចូលទៅសុំទាននៅក្នុងទេវស្ថានព្រះវិស្ណុ ហើយសុំអាហារពីព្រះវិស្ណុ។ ព្រះ

[១] Roveda 2005; Cornelia & Buitenen 1978.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

វិស្ណុបានថ្វាយឈាមដល់កន្កាលជាអាហារ និងបានកាត់សសៃឈាមមួយនៅលើថ្វាសកន្កាល ហើយឈាមក៏ហូរចូលក្នុងចានសុំទានរបស់កន្កាល។ នៅចុងបញ្ចប់ ព្រះវិស្ណុក៏បាននាំព្រះសិវភិក្ខាដនឆ្ពោះទៅកាន់ក្រុងដ៏ពិសិដ្ឋមួយឈ្មោះថា វារាណសី ដែលជាកន្លែងរលត់បាបកម្មរបស់ព្រះសិវ។ ទៅដល់ក្រុងវារាណសីលលាដ៍ព្រះសិររបស់ព្រះព្រហ្ម ក៏ធ្លាក់ចេញពីដៃរបស់ព្រះសិវនៅកន្លែងមួយដែលមានឈ្មោះថា កបល-មោចន ហើយវិស្វក្សេនក៏បានរស់ឡើងវិញ។ រីឯព្រះសិវភិក្ខាដនក៏បានលុបលាងបាបទាំងអស់នៅទន្លេគង្គាក្នុងក្រុងវារាណសី រួចត្រឡប់ទៅទេវស្ថានវិញ"។[២]

ដោយឡែក គម្ពីរផ្សេងទៀតដូចជា ស្កន្ទបុរាណ បាននិទានរឿងនេះខុសពីគម្ពីរខាងលើដែលសាច់រឿងនិទានថា៖ "នៅពេលព្រះសិវភិក្ខាដន ដើរសុំទានទាំងអាក្រាតកាយទៅដល់ព្រៃទារុកវន ទ្រង់បានឃើញក្រុមឥសីដែលរស់នៅក្នុងព្រៃទារុកវន កំពុងធ្វើពិធីសាសនាដោយក្រអឺតក្រទមនិងចាត់ទុកខ្លួនឯងថាជាព្រះ។ ដើម្បីបន្ទាបបន្ថោកឥទ្ធិពលរបស់ពួកឥសី ព្រះសិវក្នុងទម្រង់ជាអ្នកសុំទានវ័យក្មេងដ៏គួរឱ្យស្រឡាញ់ បានធ្វើដំណើរជាមួយព្រះវិស្ណុដែលបានក្លែងបន្លំខ្លួនជាប្រពន្ធរបស់ព្រះសិវដ៏មានសម្រស់ស្រស់ស្អាតនិងមានឈ្មោះថា "មោហិនិ"។ ពួកឥសីទាំងនោះបានលង់សម្រស់នាងមោហិនិយ៉ាងងប់ងល់។ នៅពេលពួកឥសីដឹងខ្លួនឡើងវិញ ពួកឥសីក៏បានធ្វើពិធីបូជាយញ្ញមួយបង្កើតជាសត្វពស់ តោ ដំរី ខ្លា និងមនុស្សតឿ ដែលសុទ្ធសឹងជាអ្នកវាយប្រហារព្រះសិវ។ ព្រះសិវភិក្ខាដន ក៏បានប្រែក្លាយទម្រង់ទៅជាទម្រង់នាដរាជរាំនៅលើមនុស្សតឿដើម្បីបង្ក្រាបអំណាចរបស់ពួកឥសី"។[៣] គម្ពីរដដែលនេះក៏រៀបរាប់ម្យ៉ាងទៀតថា "ព្រះសិវភិក្ខាដន បានកាន់ចានលលាដ៍ក្បាលព្រះព្រហ្មដើរសុំទានទាំងអាក្រាតកាយក្នុងព្រៃទារុកវន ហើយក៏បានជួបពួកព្រាហ្មណ៍កំពុងតែធ្វើពិធីបូជាយញ្ញ។ ពួកព្រាហ្មណ៍ទាំងនោះ បានព្យាយាមបណ្តេញព្រះសិវចេញពីពិធីនោះ ដោយពួកគេគិតថាអ្នកសុំទានដែលកំពុងស្រេកឃ្លានមិនសមនឹងចូលរួមពិធីនេះទេ។ ព្រាហ្មណ៍ទាំងនោះបានបោះចោលចានលលាដ៍ក្បាលទៅលើដី រំពេចនោះចានលលាដ៍ក្បាលមួយថ្មីក៏លេចឡើងជំនួស។ ក្រោយមក លលាដ៍ក្បាលរាប់រយទៀតក៏លេចចេញមកបំពុលការបូជា ទើបធ្វើឱ្យព្រាហ្មណ៍បន្ធូរចិត្តសន្យានឹងព្រះសិវថា គ្មានការបូជាណាមួយចាត់ទុកថាបានពេញលេញឡើយ ប្រសិនបើគ្មានការរំឭកដល់ព្រះសិវក្នុងទម្រង់ជា កបលេស្វរ (ព្រះអម្ចាស់នៃលលាដ៍ក្បាល)"។[៤]

---

[២] Kramrisch 1981.

[៣] Pattanaik 2001.

[៤] Kramrisch 1981.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កន្លងមក អ្នកស្រាវជ្រាវជាច្រើនធ្លាប់បានសិក្សាអំពីចម្លាក់ដែលទាក់ទងនឹងរឿងព្រះសិវភិក្សាដនមូត្តិ រួមមានដូចជា ចម្លាក់នៅប្រាសាទអង្គរវត្ត (រូបលេខ១) ចម្លាក់នៅប្រាសាទបឹងមាលា (រូបលេខ២) ចម្លាក់នៅប្រាសាទព្រះខ័ន (រូបលេខ៣) ចម្លាក់នៅប្រាសាទបាយ័ន (រូបលេខ៤) និងចម្លាក់មួយចំនួនជាច្រើនទៀត។ រូបលេខ១ ចម្លាក់នៅប្រាសាទអង្គរវត្ត សិល្បករបង្ហាញរូបព្រះសិវក្នុងទម្រង់ជាឥសីវ័យក្មេងមានរូបរាងសង្ហាឈរក្នុងមណ្ឌបដោយមានរូបចម្លាក់ក្រពើមួយនៅខាងលើមណ្ឌប ស្លៀកសំពត់ខ្លី ពាក់គ្រឿងអលង្ការពេញដងខ្លួន ព្រះហស្តខាងស្តាំលើកដាក់ត្រឹមដើមទ្រូងប្រដាប់ដោយផ្កាំ (តំណាងឱ្យកាល) រីព្រះហស្តឆ្វេងដាក់ពីក្រោមទ្រព្រះហស្តស្តាំដែលកំពុងកាន់ផ្កាំ។ នៅសងខាងព្រះសិវ-ភិក្សាដន មានចម្លាក់រូបស្ត្រីជាច្រើននាក់ឈរក្នុងកាយវិការយកដៃថ្វាយទានដល់ព្រះសិវ-ភិក្សាដន ព្រោះពេលនោះព្រះសិវគឺជាអ្នកសុំទានដែលអាក្រាតកាយ តែចម្លាក់នេះសិល្បករនៅតែឆ្លាក់ឱ្យមានសំពត់ដដែល ព្រោះខ្មែរពុំនិយមឆ្លាក់រូបទេពក្នុងទម្រង់អាក្រាតកាយឡើយ។ លោក Jean Moura (1883) និងលោក Etienne Aymonier (1903) យល់ស្របគ្នាថា ចម្លាក់នេះពុំមែនជាសាច់រឿងព្រះសិវ-ភិក្សាដនមូត្តិទេ ព្រោះលោកទាំងពីរយល់ថា ជាសាច់រឿងបង្ហាញពីក្រុងរាពណ៍ប្រែក្រឡាខ្លួនទៅជាសត្វបង្គួយ ដើម្បីចូលទៅបៃចង់មហេសីព្រះឥន្ទ្រនៅស្ថានសួគ៌។[៥] ប៉ុន្តែ ក្រោយមក លោកស្រី Madeliane Giteau សិក្សាឡើងវិញនិងយល់ថា ជារឿងព្រះសិវ-ភិក្សាដន។[៦] រូបលេខ២ ចម្លាក់ព្រះសិវ-ភិក្សាដននៅប្រាសាទបឹងមាលា បង្ហាញក្នុងទម្រង់ជាឥសីក្មេងមានរូបរាងសង្ហាឈរនៅលើជើងទម្រក្នុងមណ្ឌបមួយដែលមានសត្វក្រពើមួយក្បាលនៅពីលើ ស្លៀកសំពត់ចងក្បិន ពាក់សង្វារនៅលើព្រះកាយ ព្រះហស្តឆ្វេងកាន់អាវុធដាក់មកក្បៀកនឹងចង្កេះ រីឯព្រះហស្តស្តាំលើកឡើងលើទ្រធ្នឹមមណ្ឌបដែលមានក្រពើពីលើ។ ព្រះបាទឆ្វេងដាក់រាបស្មើ ព្រះបាទស្តាំលើកមកដាក់បញ្ឈរចុះក្រោមក្រោយព្រះបាទខាងឆ្វេង ដែលកាយវិការដាក់ព្រះបាទបែបនេះក្នុងព្រហ្មញ្ញសាសនាគេហៅថា "**ស្វស្តិកសន**"។[៧] នៅជិតព្រះសិវ មានចម្លាក់រូបស្ត្រីពីរនាក់ឈរនៅលើជើងទម្រអមសងខាង ស្លៀកសំពត់វែងមានក្បាច់លម្អនិងមានជាយធ្លាក់វែង ដៃម្ខាងច្រត់ចង្កេះ រីដៃម្ខាងទៀតកាន់អាវុធរៀងៗខ្លួន ហើយរាងកាយផ្នែកខាងលើលែងខ្លួនទទេ។ ផ្នែកខាងលើតួអង្គទាំងបី សិល្បករលម្អជាក្បាច់សន្ទឹកផ្សេងៗ ក្នុងន័យបង្ហាញអំពីព្រៃទារុកវនដែលព្រះសិវ-ភិក្សាដនបានដើរចូលទៅសុំទាន។ ចម្លាក់នេះ លោក George Coedès យល់ថា ជាចម្លាក់រឿងក្រុងរាពណ៍ប្រែក្រឡាខ្លួនទៅជាសត្វបង្គួយ ដើម្បីចូលទៅបៃចង់មហេសី

[៥] Ganapati 2002.

[៦] Moura 1883. Aymonier 1903.

[៧] Ganapati 2002.

ព្រះឥន្ទ្រនៅស្ថានសួគ៌ ដែលរឿងនេះមានរៀបរាប់នៅក្នុងគម្ពីរត្រៃភេទ។[៨] ទោះបីជាយ៉ាងណា លោក Victorio Roveda យល់ថា ជារឿងព្រះសិវ-ភិក្សាជនមូតិ។[៩]

រូបលេខ២៣ ជាសាច់រឿងដដែលនៅប្រាសាទព្រះខ័នមានលក្ខណៈដូចទៅនឹងចម្លាក់រូបលេខ២២នៅប្រាសាទបឹងមាលាដែរ។ ចម្លាក់ខាងលើបង្ហាញជាបីផ្នែក ដែលផ្នែកខាងលើបង្អស់បង្ហាញព្រះសិវ-ភិក្សាជនឈរក្នុងទម្រង់ស្វស្តិកសនក្នុងមណ្ឌប លើកព្រះហស្តម្ខាងទ្រផ្ទឹមមណ្ឌបដែលមានរូបក្រពើនៅពីលើ និងអមសងខាងដោយរូបស្ត្រីពីរនាក់លើកដៃម្ខាងថ្វាយទានមកព្រះសិវ។ ផ្នែកកណ្ដាល បង្ហាញចម្លាក់ស្ត្រីប្រាំនាក់កំពុងឈរតម្រៀបគ្នា ហាក់ដូចចង់បង្ហាញពីការរង់ចាំថ្វាយទានដល់ព្រះសិវ-ភិក្សាជន ហើយផ្នែកខាងក្រោមវិញមានរូបស្ត្រីប្រាំបួននាក់អង្គុយលើកដៃប្រណម្យត្រឹមដើមទ្រូង។

រូបលេខ២៤ ជាចម្លាក់នៅប្រាសាទបាយ័ន ក្នុងសាច់រឿងព្រះសិវ-ភិក្សាជនមូតិដូចគ្នាដែរ តែសាច់រឿងបង្ហាញក្នុងឃុតខុសពីរូបទាំងបីខាងលើ។ ចម្លាក់នៅប្រាសាទបាយ័ន បង្ហាញព្រះសិវ-ភិក្សាជន ជាឥសីវ័យក្មេងមានពុកមាត់វែងឈរក្នុងមណ្ឌបក្នុងទម្រង់ស្វស្តិកសន ស្លៀកសំពត់ចងក្បិនខ្លី ព្រះហស្តឆ្វេងលើកទ្រមណ្ឌបដែលមានសត្វក្រពើនៅពីលើផ្ទឹមមណ្ឌបដូចគ្នា រីឯព្រះហស្តស្ដាំដាក់ត្រឹមដើមទ្រូងប្រដាប់ដោយផ្កាំ។ នៅក្បែរចម្លាក់ព្រះសិវ បង្ហាញពីពួកឥសីកំពុងធ្វើពិធីអ្វីមួយ ដែលផ្នែកខាងលើគេលម្អជារូបដើមឈើផ្សេងៗក្នុងបំណងតំណាងឱ្យព្រៃទារុកវន។ ដូច្នេះចម្លាក់នេះ ឆ្លាក់ត្រាប់តាមគម្ពីរស្កន្ទបុរាណដែលនិទានថា ព្រះសិវធ្វើជាអ្នកសុំទានអាក្រាតកាយម្នាក់ឈ្មោះ "ភិក្សាជន" កាន់ចានដែលមានលលាដ៍ក្បាលព្រះព្រហ្មធ្វើដំណើរចូលព្រៃទារុកវន ក៏ទៅជួបក្រុមឥសីកំពុងធ្វើកិច្ចពិធីនិងតាំងខ្លួនជាព្រះ បន្ទាប់មកពួកឥសីក៏បណ្ដេញព្រះសិវចេញព្រោះពួកគេយល់ថាអ្នកសុំទានបែបនេះមិនសមចូលក្នុងពិធីដ៏ខ្ពង់ខ្ពស់នោះឡើយ។ ប៉ុន្តែ ចម្លាក់ខ្មែរនៅប្រាសាទបាយ័នមិនបានបង្ហាញភាពអាក្រាតកាយឡើយ ហើយក៏មិនបានបង្ហាញពីចានដែលដាក់លលាដ៍ក្បាលព្រះព្រហ្មដែរ។

រូបទាំងបួនដែលបង្ហាញខាងលើសុទ្ធសឹងជារូបចម្លាក់នៅសម័យអង្គរនាស.វ.ទី១២ និងដើមស.វ.ទី១៣ ដែលបង្ហាញផ្នែកខាងលើមានចម្លាក់រូបសត្វក្រពើដូចៗគ្នា។ ចម្ងល់នៅត្រង់ថា តើហេតុអ្វីបានសិល្បករឆ្លាក់រូបសត្វក្រពើនៅលើផ្ទឹមមណ្ឌបយ៉ាងដូច្នេះ? ព្រោះក្នុងសិល្បៈឥណ្ឌាដែលជាអ្នកនាំឥទ្ធិពលនៃសាសនាមកលើសង្គមខ្មែរនោះ គេពុំបានបង្ហាញរូបព្រះសិវ-ភិក្សាជន

[៨] Coedès 1922.

[៩] Roveda 200.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មូតិមានសត្វក្រពើនៅពីលើបែបនេះឡើយ។ ក្នុងករណីនេះ កន្លងមកមានអ្នកស្រាវជ្រាវជាច្រើន បង្ហាញនូវការយល់ឃើញផ្សេងៗពីគ្នា។ ក្នុងនោះ លោកស្រី Madeleine Giteau យល់ឃើញថា ទំនងជាគំនិតនៃការរួមបញ្ចូលគ្នារវាងវប្បធម៌ខ្មែរក្នុងតំបន់ជាមួយគំនិតនៃសាសនា ព្រោះសត្វក្រពើក្នុងគំនិតខ្មែរមានរឿងព្រេងច្រើនណាស់។[១០] ចំពោះលោក Kamaleswar Bhattacharya វិញ យល់ថា ទំនងអាចជាជំនឿអ្នកស្រុកដើមចំពោះសត្វក្រពើ ព្រោះសត្វនេះជាកម្លាំងអធិធម្មជាតិ។[១១] ក្រោយមកទៀត លោកស្រី Sandra F. Collins យល់ឃើញផ្សេងថា ទំនងជាក្រពើមានទំនាក់ទំនងច្រើនទៅនឹងតួអង្គព្រះឥសូរ។[១២] រីឯលោក Dagen Bruno យល់ថា ចម្លាក់ក្រពើនៅលើមណ្ឌបនេះ ទំនងខ្មែរឆ្លាក់ឱ្យស្របតាមរឿងជាតកដែលខ្មែរស្គាល់មួយ គឺរឿងមហាឧមគ្គជាតក ដែលមានសត្វបង្គួយមួយមានលំនៅនៅលើទ្វារចូល។[១៣] ចំណែក លោក George Coedès ក៏យល់ថា សត្វក្រពើនេះគឺជាតំណាងឱ្យសត្វបង្គួយក្នុងរឿងរាមាយណា ត្រង់ឈុតដែលក្រុងរាពណ៍ប្រែកាយជាសត្វបង្គួយទៅទុំនៅលើទ្វារក្នុងវាំងព្រះឥន្ទ្រ ក្នុងគោលបំណងទៅលួចចែចង់មហេសីព្រះឥន្ទ្រ។[១៤] ចុងក្រោយនៅក្នុងពេលថ្មីៗនេះ លោកស្រី មុយ បញ្ញា បានសាកល្បងពន្យល់រឿងនេះទៅតាមភាសាសាស្ត្រ ព្រោះសត្វក្រពើនៅក្នុងភាសាសំស្ក្រឹតគេហៅថា "នក្រ" ហើយពាក្យ "នក្រ" នេះ អាចប្រែថាសត្វក្រពើផង និងធ្នឹមទ្វារផង។ ធ្នឹម អាចក្លាយទៅជា "ទឹម" ម៉្លោះហើយទើបផ្នែកខាងចុងទូកនៅក្រោមនឹមរទេះគេហៅថា "ក្បាលក្រពើ"។ លោកស្រីយល់ថា ការដែលសិល្បករបុរាណខ្មែរឆ្លាក់រូបសត្វក្រពើនៅលើធ្នឹមទ្វារដូច្នេះ អាចមកពីគេយល់ថា "នក្រ" ប្រែថា "ធ្នឹមទ្វារ" ហើយទំនងអ្នកឆ្លាក់គេយល់ច្បាស់អំពីភាពមិនស្ថិតស្ថេរនៃសំណង់ប្រាសាទ។[១៥]

ទោះបីជាយ៉ាងណា រូបអម្បាលម៉ានដែលបានបង្ហាញខាងលើ គឺសុទ្ធសឹងតែជាចម្លាក់នៅសម័យអង្គរ ក្នុងស.វ.ទី១២ ឬចុងទី១៣ តែប៉ុណ្ណោះ។ ដូច្នេះហើយ សំណួរអាចលើកឡើងថា តើនៅសម័យមុនអង្គរក្នុងរវាងស.វ.ទី៦ ដល់ស.វ.ទី៨ មានចម្លាក់រឿងព្រះសិវ-ភិក្សាដន បង្ហាញនៅតាមប្រាសាទដែរឬទេ? យើងពិបាកនឹងកំណត់ថាតើចម្លាក់រឿងនេះនៅសម័យមុនអង្គរ មានដែរឬអត់នោះឡើយ ប៉ុន្តែ នៅតំបន់ប្រាសាទសំបូរព្រៃគុកមានចម្លាក់ចំនួនពីរដែលបង្ហាញសាច់រឿងប្រហាក់ប្រហែលរឿងព្រះសិវ-ភិក្សាដនមូតិ។ ចម្លាក់ទី១ (រូបលេខ៩) ជាចម្លាក់លើវិមានអណ្តែត

---

[១០] Giteau 1965.

[១១] Kamaleswar 1966.

[១២] Collins 1976.

[១៣] Dagen 1969.

[១៤] Coedès 1922.

[១៥] មុយ បញ្ញា ២០១៦។

ជញ្ជាំងខាងត្បូងផ្នែកខាងកើតនៃប្រាសាទដើមច័ន្ទ (តួប៉ម N15) នៅជាន់ខាងលើបង្អស់បង្ហាញអំពីរូបទេពប្រុសម្នាក់ពាក់មកុដរាងស៊ីឡាំងឈរក្នុងកាយវិការរាងកាច់ចង្កេះឬហៅថា "ត្រិភង្គ" ស្ទៀកសំពត់ខ្លីមានជាយធ្លាក់ចំពាក់កណ្តាល ព្រះហស្តស្តាំអាវុធម្យ៉ាងស្រដៀងដំបងដែលខាងចុងមានរាងដូចផ្កាឈូក រីឯព្រះហស្តឆ្វេងដាក់កៀកលើស្មាស្ត្រីម្នាក់ដែលកំពុងឈរនៅខាងស្តាំទេពនៅកណ្តាល ដែលរូបទេពប្រុសនៅចំពាក់កណ្តាលនេះទំនងជារូបព្រះសិវក្នុងទម្រង់ភិក្សាជនមូតិ។ រីឯនៅខាងឆ្វេងទេពប្រុសនៅចំកណ្តាល បង្ហាញជារូបស្ត្រីម្នាក់មានរូបរាងស្រស់ស្អាត ព្រះហស្តឆ្វេងដាក់សំយ៉ុងទៅក្រោម និងព្រះហស្តស្តាំកាន់វត្ថុអ្វីម្យ៉ាងមានរាងមូលស្រដៀងនឹងកងចក្រ។ រូបស្ត្រីនៅខាងឆ្វេងនេះ ទំនងជាព្រះវិស្ណុដែលប្រែក្រឡាជាស្ត្រីស្រស់ស្អាតម្នាក់ឈ្មោះ "មោហិនិ" ដែលដើរកំដរព្រះសិវចូលសុំទានក្នុងព្រៃទារុកវន ឬបើមិនមែនជាតួអង្គព្រះវិស្ណុមោហិនិទេ ក៏ទំនងជារូបប្រពន្ធរបស់ឥសីដែលមកដាក់ទានដល់ព្រះសិវ-ភិក្សាជន។ រូបស្ត្រីខាងស្តាំ ទំនងជារូបប្រពន្ធឥសីដែលលង់ស្នេហ៍លើព្រះសិវ។ ចំណែក រូបតួអង្គខាងចុងសងខាងពីរទៀតកំពុងឈរដោយមានដៃកាន់ក្អម ជាចំណុចមួយដែលអាចឱ្យយើងគិតថាគឺជារូបស្ត្រីដែលកាន់ទេយ្យទានមកថ្វាយចំពោះព្រះសិវក្នុងទម្រង់ជាអ្នកសុំទាន។ រូបស្ត្រីកាន់ក្អមរបៀបនេះ មានលក្ខណៈស្រដៀងទៅនឹងរូបមួយនៅប្រាសាទមធុកេស្វរ នៅក្នុងសិល្បៈឥណ្ឌា ដែលគេបង្ហាញស្ត្រីចំនួន ៦ នាក់ ខ្លះកាន់ក្អម និងខ្លះកាន់ទេយ្យទានផ្សេងទានមកថ្វាយជាទានដល់ព្រះសិវ-ភិក្សាជន (រូបលេខ២៦)។ ដោយឡែកអាវុធដែលតួអង្គទេពប្រុសដែលបានរៀបរាប់ខាងលើកាន់នឹងព្រះហស្តនេះទៀតសោត ក៏មានលក្ខណៈស្រដៀងអាវុធដែលកាន់ដោយព្រះសិវ-ភិក្សាជន នៅប្រាសាទដៃបុរ នៃសិល្បៈឥណ្ឌាទៀតផង (រូបលេខ២៧)។

ចម្លាក់មួយផ្ទាំងទៀត (រូបលេខ២៨) គឺជាចម្លាក់នៅលើផ្តែរដែលគេទើបនឹងរកឃើញថ្មីនៅខ្លោងទ្វារកំពែងខាងលិចនៃក្រុមប្រាសាទសំបូរ (ក្រុមខាងជើង) ដែលបង្ហាញអំពីរូបទេពប្រុសមួយនៅចំកណ្តាលអង្គុយក្នុងកាយវិការមួយហៅថា "មហារាជលីលាសន" (Mahãrãjalĩlãsana) (ជើងស្តាំបញ្ឈរជង្គង់និងជើងឆ្វេងដាក់រាបស្មើមកផ្ទឹបជាមួយបាទជើងស្តាំ) និងអមដោយរូបស្ត្រីចំនួនបីនាក់នៅខាងឆ្វេង ហើយខាងស្តាំមានចំនួន ៤ នាក់ (សរុប ៧នាក់)។ រូបទេពប្រុសនៅកណ្តាលអាចជា ព្រះសិវក្នុងទម្រង់ភិក្សាជន (?) ហើយរូបស្ត្រីជុំវិញអាចបង្ហាញពីប្រពន្ធឥសីដែលមកថ្វាយទាន

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ដល់ព្រះសិវក្នុងពេលកំពុងសុំទាន។ រូបលេខ៨ នេះ យើងពិនិត្យឃើញថា ទេពប្រុសអង្គុយកាយវិការមហារាជលីលាសនដូចគ្នាជាមួយរូបនៅប្រាសាទមធុកេស្វរ ក្នុងសិល្បៈឥណ្ឌា។[១៦]

យ៉ាងណាក៏ដោយ រូបបង្ហាញទាំងពីរជាសិល្បៈសម័យមុនអង្គរដែលបង្ហាញខាងលើគ្រាន់តែជាការសន្និដ្ឋានជាបឋមប៉ុណ្ណោះ តែរូបទាំងពីរនេះមានលក្ខណៈប្រហាក់ប្រហែលជាមួយរូបនៅឥណ្ឌាទាំងអម្បាលម៉ានដែលបានបង្ហាញជាហេតុដែលយើងអាចសាកល្បងសន្និដ្ឋាន។ ក្នុងនោះដែរ ប្រសិនបើរូបទាំងពីរនេះ ពិតជារូបព្រះសិវក្នុងទម្រង់ភិក្សាដនមែននោះ យើងនឹងអាចនិយាយបានថា រូបព្រះសិវ-ភិក្សាដនមូតិនៅសិល្បៈសម័យមុនអង្គរ មានលក្ខណៈខុសគ្នាច្រើនពីការបង្ហាញរូបចម្លាក់ព្រះសិវ-ភិក្សាដនមូតិនៅសម័យអង្គរ (ស.វ.ទី១២ និងដើមស.វ.ទី១៣) ហើយអ្វីជាការចាប់អារម្មណ៍នោះ នៅសម័យមុនអង្គរពុំមានចម្លាក់រូបសត្វក្រពើដូចនៅសម័យអង្គរ។

ជាសរុបមក ព្រះសិវ-ភិក្សាដនមូតិ គឺជាទម្រង់មួយដែលព្រះសិវប្រែក្រឡាខ្លួនទៅជាឥសីវ័យក្មេងមានរូបរាងសង្ហា ដើរសុំទាននៅស្ថានទាំងបីដោយភាពអាក្រាតកាយ ដើម្បីលុបលាងបាបរបស់ទ្រង់ដែលបានកាត់ព្រះសិរព្រះព្រហ្ម។ ប៉ុន្តែ ចម្លាក់នៅក្នុងសិល្បៈខ្មែរដែលបានបង្ហាញទាំងអម្បាលម៉ានគេមិនបានបង្ហាញរូបព្រះសិវ-ភិក្សាដនជាឥសីអាក្រាតកាយនោះឡើយ ព្រោះខ្មែរយើងពុំនិយមការឆ្លាក់អាក្រាតកាយដូចសិល្បៈឥណ្ឌាឡើយ។ អ្វីដែលកត់សម្គាល់នោះ នៅសម័យអង្គរ គេតែងតែឆ្លាក់រូបព្រះសិវឈរក្នុងមណ្ឌបមួយដែលមានរូបសត្វក្រពើនៅលើធ្នឹមមណ្ឌប។ ទោះបីជាយ៉ាងណា រូបសត្វក្រពើនេះ គេពុំអាចពន្យល់អំពីគំនិតឱ្យបានច្បាស់លាស់នៅឡើយទេ។ ប៉ុន្តែ យើងគ្រាន់តែដឹងថានៅក្នុងគំនិតខ្មែរ គេតែងចាត់ទុកក្រពើជាសត្វរមិលគុណ ឬពាក្យមួយដែលគេតែងនិយាយថា "ក្រពើរវង្វេងបឹង" មានន័យថា ក្រពើជានិមិត្តរូបនៃភាពវង្វេងវង្វាន់ ហេតុដូច្នេះហើយ ការដែលគេឆ្លាក់រូបក្រពើនៅលើធ្នឹមមណ្ឌបក្រោមដើមឈើដូចករណីរូបនៅបាយ័ន អាចចង់សំដៅដល់ការវង្វេងរបស់ព្រះសិវនៅក្នុងព្រៃទារុកវន រហូតដល់ថ្នាក់ល្បួងប្រពន្ធឥសីឱ្យងប់ងល់នឹងសម្រស់ទ្រង់ក៏ថាបាន។ ដោយឡែក សម្រាប់ចម្លាក់ព្រះសិវ-ភិក្សាដនមូតិនៅសម័យមុនអង្គរ ដែលយើងបង្ហាញទាំងពីរខាងលើ គឺគ្រាន់តែជាការសន្និដ្ឋានបឋមតែប៉ុណ្ណោះ៕

---

[១៦] Thomas 1986.

# ឯកសារយោង

**មុយ បញ្ញា**

២០១៦, *ចម្លាក់ក្រពើក្នុងសិល្បៈខ្មែរបុរាណ, ភ្នំពេញ។*

**Aymonier, Etienne**

1903, *Le Cambodge, Le royume actuel,* Tome III, Paris.

**Cornelia & Buitenen, J.A.B**

1978, Classical Hindu Mythology, New York.

**Dagen, Bruno**

1969, 'Etude sur l'iconographie du Bayon (Frontons et linteau)', *Art Asiatiques,* Tome 19, Paris.

**George, Coedès**

1922**,** 'Notes sur iconographie de Ben Mala', *Article sur le pays Khmer,* Tome II, Paris.

**Madeleine, Giteau**

1965, 'Une representation de la Bhikatanamurti de Shiva à Angkor Vat', *Art Asiatiques,* Tome XI, Paris.

**Moura, Jean**

1883, *Le royaume du Cambodge,* Paris.

**Roveda, Victorio**

2005, "*Image of the gods*", Bangkok

**Sandra F., Collins**

1976, *The Lizard-Portal motif: Its meaning and function,* Thesis of master in USA.

**Thomas E. Donaldson**

1986, 'Bhiksatanamurti Image from Orissa', *Artibus Asiae,* Vol 47.



រូបលេខ១៖ ចម្លាក់ព្រះសិវភិក្សាជនមូតិ៌នៅប្រាសាទអង្គរវត្ត (រូបថត៖ លួន ទីឃា)



រូបលេខ២៖ ចម្លាក់ព្រះសិវភិក្សាជនមូតិ៌នៅលើសសរផ្ដោបប្រាសាទបឹងមាលា (រូបថត៖ នូ សុគីន)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៣៖ ចម្លាក់ព្រះសិវៈភិក្សាដនមូតិនៅលើហោជាងប្រាសាទព្រះខ័ន



រូបលេខ២៤៖ ចម្លាក់ព្រះសិវៈភិក្សាដនមូតិនៅលើថែវប្រាសាទបាយ័ន (រូបថត៖ ឡុន ណាក់)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ លម្អិតសត្វក្រពើនៅលើថែវប្រាសាទបាយ័ន (រូបថត៖ ឡុន ណាក់)



រូបលេខ២៥៖ ចម្លាក់ព្រះសិវភិក្សាដនមូតិ៍(?)នៅលើវិមានអណ្ដែតប្រាសាទដើមចាន់ (សំបូរព្រៃគុក)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ចម្លាក់ព្រះសិវភិក្សាជនមូតិនៅប្រាសាទមធុកេស្វរ ប្រទេសឥណ្ឌា (ប្រភព៖ Thomas 1986)



រូបលេខ២៧៖ ចម្លាក់ព្រះសិវភិក្សាជនមូតិនៅប្រាសាទដៃបុរ ប្រទេសឥណ្ឌា (ប្រភព៖ Thomas 1986)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី